# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៤៤...សសរ

## សេចក្ដីសំរេច
## ស្ដីពី
## ការបង្កើតគណៈកម្មការរៀបចំពិព័រណ៍វប្បធម៌ពិភពលោក អង្គរ-ឃ្យុងយូ ២០០៦
## (Organizing Committee for Angkor-Gyeongju World Cultural Expo 2006)
## នៅខេត្តសៀមរាប ឆ្នាំ២០០៦-២០០៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន/ស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- យោងតាមតំរូវការចាំបាច់

## សំរេច

**ប្រការ ១:** បង្កើតគណៈកម្មការអន្តរក្រសួង (Organizing Committee) ដើម្បីរៀបចំការតាំងពិព័រណ៍វប្បធម៌ពិភពលោក អង្គរ-ឃ្យុងយូ ២០០៦ (Angkor-Gyeongju World Cultural Expo 2006) នៅខេត្តសៀមរាប ដែលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្ដម **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ប៉ាណារ៉ា ស៊ីរីវុឌ្ឍ** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣- ឯកឧត្ដម **ឡាយ ប្រាហស្ថ** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤- ឯកឧត្ដម **សេខ លីមនៅ** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៥- ឯកឧត្ដម **ញ៉ឹ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៦- ឯកឧត្ដម **ថោង ខុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៧- ឯកឧត្ដម **មីន ឃិន** | រដ្ឋលេខាធិការក្រសួងធម្មការ និងកិច្ចការសាសនា និងជាអគ្គលេខាធិការគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ | សមាជិក |
| ៨- ឯកឧត្ដម **ជុច ភឿន** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៩- ឯកឧត្ដម **ម៉ៅ អាយុទ្ធ** | រដ្ឋលេខាធិការក្រសួងពត៌មាន | សមាជិក |
| ១០- ឯកឧត្ដម **ស៊ូ ម៉ារ៉ា** | អគ្គលេខាធិការ អាជ្ញាធរជាតិទេសចរណ៍ | សមាជិក |

| | | | |
|---|---|---|---|
| ១១- ឯកឧត្តម | **ម៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយ និងរដ្ឋាករ | សមាជិក |
| ១២- ឯកឧត្តម | **ស៊ឹម សុន** | អភិបាលខេត្តសៀមរាប | សមាជិក |
| ១៣-ឯកឧត្តម | **នឹម ចំនួតារា** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៤- ឯកឧត្តម | **ទី តាឃី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៥- ឯកឧត្តម | **សយ សុខាន់** | អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៦- ឯកឧត្តម | **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៧- ឯកឧត្តម | **នេត សាវឿន** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១៨-ឯកឧត្តម | **ប៊ុន ណារិទ្ធ** | អគ្គនាយកអាជ្ញាធរអប្សរា | សមាជិក និងជាប្រធានលេខាធិការដ្ឋាន |
| ១៩-ឯកឧត្តម | **អ៊ុក សុវមេត្ត** | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក និងជាអនុប្រធានលេខាធិការដ្ឋាន |
| ២០-ឯកឧត្តម | **ម៉ី ម៉ារ៉ាឌី** | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក និងជាអនុប្រធានលេខាធិការដ្ឋាន |

**ប្រការ ២:** គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម:

- សហការជាមួយភាគីកូរ៉េ ដើម្បីរៀបចំពិព័រណ៍វប្បធម៌ពិភពលោក អង្គរ-ឃ្យុងជូ ២០០៦-២០០៧ ការសំដែងសិល្បៈ សកម្មភាព និងទស្សនីយភាពផ្សេងៗ អោយបានជោគជ័យល្អប្រសើរ
- សហការជាមួយផ្នែកឯកជន ដើម្បីរៀបចំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធបំរើអោយព្រឹត្តិការណ៍នេះ និងធ្វើការឃោសនា និងផ្សព្វផ្សាយអំពីព្រឹត្តិការណ៍នេះអោយបានទូលំទូលាយ ទាំងក្នុងប្រទេស និងក្រៅប្រទេស
- រៀបចំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ សណ្តាប់ធ្នាប់ អនាម័យ នៅទីក្រុងសៀមរាប អោយបានស្អាតល្អ ដើម្បីទទួលភ្ញៀវទេសចរជាតិ និងអន្តរជាតិ
- រៀបចំសំរួលការធ្វើដំណើរ និងទទួលស្វាគមន៍គណៈប្រតិភូ និងភ្ញៀវទេសចរដែលមកចូលរួមក្នុងព្រឹត្តិការណ៍នេះអោយបានល្អ
- បូកសរុបចំណូល និងចំណាយ ព្រមទាំងរាយការណ៍អំពីលទ្ធផលជូនប្រមុខរាជរដ្ឋាភិបាល

**ប្រការ ៣:** គណៈកម្មការមានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញនានា តាមតំរូវការចាំបាច់របស់ខ្លួន ។

**ប្រការ ៤:** ប្រធានគណៈកម្មការត្រូវបង្កើតលេខាធិការដ្ឋាន ដែលជាសេនាធិការរបស់ខ្លួន មានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៥:** គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៦:** សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ ៧:** គណៈកម្មការនេះត្រូវចប់ភារកិច្ច និងត្រូវរំសាយជាស្វ័យប្រវត្តិ នៅពេលចប់ព្រឹត្តិការណ៍នេះ ។

**ប្រការ ៨:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ប្រធានអគ្គនាយកអាជ្ញាធរអប្សរា ប្រធានអាជ្ញាធរជាតិទេសចរណ៍កម្ពុជា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយ និងរដ្ឋាករ សាលាខេត្តសៀមរាប ក្រសួង ស្ថាប័ន អាជ្ញាធរ ពាក់ព័ន្ធ ព្រមទាំងឯកឧត្តម អស់លោកដែលមានរាយនាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ*
- *ឯកសារ-កាលប្បវត្តិ*